**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងព្រហ្មទណ្ឌលេខ ៨០៤០
ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ ៤៤២៨
ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ ១៦៤២
ចុះថ្ងៃទី០៣ខែមេសា ឆ្នាំ២០២០
-សាលក្រមលេខ: ៨០៨ "ទ" ក្រ១០
ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

## នាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ដោយមានសមាសភាពចូលរួមដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ **ប្រធានក្រុមប្រឹក្សា**
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ **ចៅក្រមប្រឹក្សា**
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ **ចៅក្រមប្រឹក្សា**

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខ ៨០៤០ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ:

**១**-ឈ្មោះ [redacted] **ប៊ុនថា** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មកររោងចក្រ ទីកន្លែងកំណើតនៅ ភូមិ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះសំណាក់ម៉េងហុង សង្កាត់កន្ទោក ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ថន** "រ" ម្តាយឈ្មោះ [redacted] **ផុន** "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ១៣៤៣៦ "ទ" ដឃដ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ មណ្ឌលអប់រំកែប្រែទី០១ (ម១)។

**២**-ឈ្មោះ [redacted] **ភ័ក្រ្ត** ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ សង្កាត់[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះសំណាក់ម៉េងហុង សង្កាត់កន្ទោក ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] **យិន** "ស្លាប់" ម្តាយឈ្មោះ [redacted] **ភាព** "រ" នៅលីវ ជា**អនីតិជន** ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ១៣៤៣៧ "ទ" ដឃដ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ មណ្ឌលអប់រំកែប្រែទី០២ (ម២)។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទជាអនីតិជន ឈ្មោះ [redacted] ភ័ក្រ្ត ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទជាអនីតិជន ឈ្មោះ [redacted] ភ័ក្រ្ត ។

### អង្គហេតុនៃរឿងដើមមានដូចតទៅ:

កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១៩ និង ៣៥នាទី នៅចំណុចផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើងដែល ប្រព្រឹត្តដោយ

ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា និងឈ្មោះ [redacted] ភ័ក្រ្តនិងបានដកហូតវត្ថុតាងក្រោមពណ៌សថ្លាចំនួន ០១កញ្ចប់ ទម្ងន់ ០,១៨ ១ (សូន្យក្បៀសដប់ប្រាំបី)ក្រាម យកមកសាកសួរនៅមន្ទីរប្រឆាំងគ្រឿងញៀន ។

-បានឃើញរបាយការណ៍សំយោគលេខ៤២២១ របក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩របស់មន្ត្រីនគរបាលយុត្តិធម៌។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៥៤៨៨ អ.យ.ណ ចុះថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ពាពរលេខ: ៩៩៥ អ.យ.ណ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ១៦០៦ "ភ" ដ.ដ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ភ័ក្រ្ត បានឆ្លើយថា: កាលពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៩វេលាម៉ោង ១៩និង៣៥នាទីល្ងាចសមត្ថកិច្ចបានចាប់ខ្លួនឈ្មោះ [redacted] ប៊ុនថា ដែលកំពុងអង្គុយ លើម៉ូតូចាំម៉ូយមកយកគ្រឿងញៀនសមត្ថកិច្ចបានដកហូតយគ្រឿងញៀនប្រភេទម៉ាទឹកកកចំនួនមួយកញ្ចប់។គ្រឿងញៀន នេះខ្លួន និងឈ្មោះ [redacted] ប៊ុនថា បានទិញពីឈ្មោះ **ពេជ្រ** មិនស្គាល់អត្តសញ្ញាណក្នុងតម្លៃ ៤,០០០០ រៀល ហើយពួកខ្លួន យកទៅលក់បន្ត ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល០១ ឆ្នាំមកហើយ ។កន្លងខ្លួនធ្លាប់ជួញដូរគ្រឿងញៀន ០៣ខែ មកហើយ ។ សំណូមពរចុងក្រោយសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថា** បានឆ្លើយសារភាពនាពេលសវនាការថា៖កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១៩និង៣៥នាទីល្ងាច ខ្លួនបានជិះម៉ូតូឌុបឈ្មោះ [redacted] សុភ័ក្រ្ត ក្នុងគោលបំណងយកគ្រឿងញៀនពីឈ្មោះ **ពេជ្រ** នៅម្តុំកំបូលទៅឱ្យម៉ូយ តែមិនទាន់បានឱ្យម៉ូយផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួននិងឈ្មោះ [redacted] ភ័ក្រ្ត តែម្តង ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ, លទ្ធផលកោសលវិច្ច័យ ព្រមទាំងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យលោកចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានធ្វើសេចក្តីសន្និដ្ឋានការពារ និងស្នើសុំថា៖ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់កូនក្តីពួកខ្លួនឈ្មោះ [redacted] សុភ័ក្រ្ត នៅពេលសួរដេញដោលនាពេលសវនាការ ឃើញថាកូនក្តីពួកខ្លួនមានស្មារតីភ្ញាក់រលឹកដឹងពីកំហុសរបស់គាត់ខ្វះការយល់ដឹង និងការឆ្លើយនៅគ្រប់ដំណាក់កាលស៊ើបសួរ ក៏ឆ្លើយសារភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុពេលសវនាការ មិនធ្វើឱ្យមានការស្មុគស្មាញដល់លោកប្រធានក្រុមប្រឹក្សាជំនុំជម្រះពិបាកឡើយ ហើយកូនក្តីពួកខ្លួនគឺជាអនិតិជនអាយុទើបតែ ១៥ ឆ្នាំ ខ្វះការយល់ដឹងបានកាន់គ្រឿងញៀនត្រឹមតែ ០,១៨ក្រាម (សូន្យក្បៀសដប់ប្រាំបីក្រាម) ប៉ុណ្ណោះ ហើយការរកស៊ីគឺគ្រាន់តែជាបរចិញ្ចឹមជីវិតបណ្តោះ ដូច្នេះពួកខ្លួនជាមេធាវីការពារជនជាប់ចោទធ្វើការស្នើសុំឱ្យលោកប្រធានមេត្តាពិចារណាលើស្ថានសម្រាលទោសនៃច្បាប់ស្តីពី សិទ្ធការពារអនីតិជន និងសិទ្ធកុមារ ដូច្នេះស្នើសុំឱ្យលោកប្រធានមេត្តាសម្រេចឱ្យកូនក្តីពួកខ្លួនរួចខ្លួនលើបទចោទប្រកាន់តាមមាត្រា ៥ ចំណុចទី៥ និងមាត្រា ៦០ ស្តីពីយុត្តិធម៌អនីតិជន និងតាមមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានធ្វើសេចក្តីសន្និដ្ឋានការពារ និងស្នើសុំថា៖ កូនក្តីខ្លួនជាអនីតិជនពុំមានស្មារតីគ្រប់គ្រាន់ទទួលខុសត្រូវនៅលើបទល្មើសព្រហ្មទណ្ឌឡើយ ហើយខ្វះការយល់ដឹង និងមានស្មារតីស្មោះត្រង់បានឆ្លើយសារភាពជូនលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងនៅចៅក្រមស៊ើបសួរមិនធ្វើឱ្យមានការស្មុគស្មាញក្នុងការសួរដេញដោលឡើយ ដូច្នេះស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ ពិចារណាពីស្ថានសម្រាលទោសក្នុងអតិប្បរមាទាបបំផុត តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** បាននិយាយសម្តីចុងក្រោយថា៖ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## យល់ឃើញថា

១-ពិតជាមានអង្គហេតុកាលពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៩វេលាម៉ោង ១៩និង៣៥នាទីល្ងាច កម្លាំងសមត្ថកិច្ចនគរបាលខណ្ឌពោធិ៍សែនជ័យ បានធ្វើការបង្ក្រាបករណីជាក់ស្តែងនូវករណី ជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវបេតុង សង្កាត់បន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ ឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** និងដកហូតវត្ថុតាងជាថ្នាំញៀនចំនួន ០១កញ្ចប់ ដែលមានទម្ងន់សរុប ០,១៨ (សូន្យក្បៀសប្រាំបី) ក្រាម ពិតប្រាកដមែន រីឯបក្សពួក ឈ្មោះ ពេជ្រ គ្មានអត្តសញ្ញាណលើកលែងចោទប្រកាន់ និងត្រូវបានចៅក្រមស៊ើបសួរ បញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** មកជំនុំជម្រះក្នុងអង្គហេតុនេះផងដែរនេះ បើយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៥៤៨៨ អ.យ.ណ ចុះថ្ងៃទី១៩ ខែវិច្ឆិកាឆ្នាំ២០១៩ ដីកាសន្និដ្ឋានស្ថាពរ លេខ ៩៩៥ អ.យ.ណ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២០ របស់តំណាងអយ្យការ និងដីកាសម្រេចបញ្ជូនសំណុំរឿងជំនុំជម្រះលេខ ១៦០៦ ភ ដ.ង ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ព្រមទាំងរបាយការណ៍របស់មន្រ្តីនគរបាល យុត្តិធម៌មន្ទីរប្រឆាំងគ្រឿងញៀនលេខ ៤២២១ របក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៩ គឺជាភស្តុតាងសម្រាប់ដាក់បន្ទុក មានលក្ខណៈគ្រប់គ្រាន់ ។

២-ជនជាប់ចោទឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** បានឆ្លើយថា៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនពិតជាបានទិញគ្រឿងញៀនពីឈ្មោះ **ពេជ្រ** ក្នុងតម្លៃ ៤០០០០៛ ដើម្បីយកទៅឱ្យម៉ូយពិតប្រាកដមែន នៅម្តុំសង្កាត់បន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ តាមការឆ្លើយសារភាពមានភាពស៊ីសង្វាក់ ជាមួយអង្គហេតុ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ តុលាការពិនិត្យឃើញថា ជនជាប់ចោទ ទទួលស្គាល់ភស្តុតាង គ្រឿង ញៀនតែគ្រឿងញៀន ត្រូវបានដកហូត ពីជនជាប់ចោទ ដោយមន្រ្តីនគរបាលយុត្តិធម៌ និងមានពាក់ព័ន្ធជាមួយ ឈ្មោះ ពេជ្រ ដែលត្រូវសមត្ថកិច្ចតាមរក និងមានការតាមចាប់ខ្លួនទៀតផង។ តាមការពិនិត្យលើកាលៈទេសៈនៃបទល្មើសឃើញថាជនជាប់ ចោទ ឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** និងជនជាប់ចោទឈ្មោះ ពេជ្រ (គ្មានអត្តសញ្ញាណ) តែងតែ ជួញដូរ នូវសារធាតុញៀនច្រើនដង មានបទល្មើសច្បាស់លាស់ ក្នុងរឿងគ្រឿងញៀននេះដែលឱ្យតុលាការ ជឿបានថា អ្នកទាំងនេះពិតជាជួញដូរនូវសារធាតុញៀនហើយចម្លើយរបស់ឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** ជាចម្លើយឱ្យតុលាការជឿ បើធ្វើការពិនិត្យលើភស្តុតាង និងចម្លើយសារភាព រួមទាំងធាតុផ្សំបទល្មើសមានសលក្ខខ័ណ្ឌគ្រប់គ្រាន់ ។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** កំណត់ហេតុដកហូតវត្ថុតាង ព្រមទាំងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជាភស្តុតាងដាក់បន្ទុកមានលក្ខណៈគ្រប់គ្រាន់ដែលគប្បីលើកយកមកពិចារណា ។

៤-ពិនិត្យលើសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** បានយកថ្នាំញៀនពីឈ្មោះ **ពេជ្រ** ដើម្បីជួញដូរឱ្យទៅម៉ូយដើម្បីទទួលបានប្រាក់ចំណេញ ខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀនដែរ ដែលអំពើនេះគឺជាការប្រព្រឹត្តដោយចេតនានូវបទល្មើស "**ជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន**" ដែលច្បាប់បញ្ញត្តិឱ្យនិយមន័យ និងផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង។



Scanned with CamScanner

៥-អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងធ្វើឱ្យប៉ះពាល់ដល់សតិអារម្មណ៍សុខមាលភាពប្រជាពលរដ្ឋ ហើយត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន តាមការគណនាពិនិត្យកម្រិតធាតុសុទ្ធនៃសារធាតុញៀនមាន $= \frac{០,១៨ \times ៧៨,៧៥}{១០០} =$ ០,១៤ក្រាម គប្បីតុលាការលើកយកមកពិនិត្យពិចារណា ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភ័ក្រ្ត និងឈ្មោះ [redacted] ប៊ុនថា ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង សង្កាត់បន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង ញៀន ។

៨-ជនជាប់ចោទឈ្មោះ [redacted] ភ័ក្រ្ត ភេទ ប្រុស អាយុ ១៥ឆ្នាំ **ជាអនីតិជនខ្វះការយល់ដឹង** ពុំទាន់សមត្ថភាពគ្រប់គ្រាន់ ដើម្បីទទួលខុសត្រូវទណ្ឌកម្មក្នុងអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដូច្នេះតុលាការគប្បី ពិចារណាអំពីស្ថានសម្រាលទោសដល់ជន ជាប់ចោទតាមមាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានសន្និដ្ឋានអំពីអង្គហេតុ និងធាតុផ្សំនៃបទល្មើសហើយបានសំណូមពរសុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទមានលក្ខណៈត្រឹមត្រូវតាមច្បាប់គប្បីលើកយកមកពិចារណា ។

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**ឈ្មោះ** [redacted] **ភ័ក្រ្ត** បានធ្វើសេចក្តីសន្និដ្ឋានការពារថានិងស្នើសុំថា៖ ស្នើសុំឱ្យលោកប្រធានមេត្តាពិចារណាពីស្ថានសម្រាលទោសដល់កូនក្តីរបស់ខ្លួនដែលគឺជា អនីតិជនការស្នើសុំគប្បីតុលាការពិចារណាតាមមាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសម្រាលទោសជនជាប់ចោទខ្លះ ។

១១-ជនជាប់ចោទឈ្មោះ [redacted] **ភ័ក្រ្ត** និងឈ្មោះ [redacted] **ប៊ុនថា** បាននិយាយសម្តីចុងក្រោយថា៖ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្លួនផងគប្បីពិចារណា ។

១២-វត្ថុចាប់យក៖ ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យក ដូចមាននៅក្នុងកំណត់ហេតុវត្ថុចាប់យកលេខ ៣៦៤៣ ន.វ.ត ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ត្រីទទួលបន្ទុកវត្ថុចាប់យកមាន:

ក. ស្រោមសំបុត្រពណ៌គគីបិទជិតសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមសធ្លាទម្ងន់ 0.១៨ ក្រាម (សូន្យក្បៀសដប់ប្រាំបីក្រាម) ។

ខ. ម៉ូតូម៉ាក SUZUKI SEX ពណ៌សលាយខ្មៅ ពាក់ស្លាកលេខ កំពង់ស្ពឺ 1I-5548 ចំនួន ០១ គ្រឿងដូចមាននៅក្នុងរបាយការណ៍លេខ ៤២២១ ន.ប.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀន (ក.៦) ។

-គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## **វិនិច្ឆ័យសេចក្តីសម្រេច**

**១-ផ្តន្ទាទោសលើឈ្មោះ ៖**

ក.ឈ្មោះ [redacted] **ភ័ក្រ្ត** ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ជា**អនីតិជន** (ដែលមានអត្តសញ្ញាណនៅក្នុងសំណុំរឿងស្រាប់) ដាក់ពន្ធនាគាកំណត់ ០១ ឆ្នាំ (មួយ) ឆ្នាំ ។

**ខ.**ឈ្មោះ [redacted] **ប៊ុនថា** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ (ដែលមានអត្តសញ្ញាណនៅក្នុងសំណុំរឿងស្រាប់) ដាក់ពន្ធនាគារកំណត់ ០២ ឆ្នាំ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤,000,000 រៀល (បួនលាន) រៀល ។

ក្នុងអង្គហេតុ "**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅចំណុចផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២**-វត្ថុចាប់យក៖ ដូចមាននៅក្នុងកំណត់ហេតុវត្ថុចាប់យកលេខ ៣៦៤៣ ន.វ.ត ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ត្រីទទួលបន្ទុកវត្ថុចាប់យកមាន:



Scanned with CamScanner

ក. ស្រោមសំបុត្រពណ៌គគីបិទជិតសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមសថ្លាទម្ងន់ ០.១៨ ក្រាម (សូន្យក្បៀសដប់ប្រាំបីក្រាម) ត្រូវរឹបអូសបំផ្លាញចោល ។

ខ. ម៉ូតូម៉ាក SUZUKI SEX ពណ៌សលាយខ្មៅ ពាក់ស្លាកលេខ កំពង់ស្ពឺ 1I-5548 ចំនួន ០១ គ្រឿងដូចមាននៅក្នុងរបាយណ៍លេខ ៤២២១ រ.ប.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីប្រឆាំងគ្រឿងញៀន (ក.៦) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភ័ក្រ្ត និងជនជាប់ចោទឈ្មោះ [redacted] ប៊ុនថា ។

បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ចន្ទ ៨ រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]